# ដំណឹងល្អ។

## ធុងថ្មីពណ៌បៃតងនិងកូនធុងសំរាម សម្រាប់ចង្ក្រានបាយរបស់អ្នកនឹងមកដល់ នៅចន្លោះខែមេសានិងឧសភា ឆ្នាំ 2024

## ហើយធុងពណ៌ក្រហមរបស់អ្នកនឹងនៅតែដដែល!




**FOGO**

សារធាតុសរីរាង្គអាហារ
សារធាតុសរីរាង្គសួនច្បារ
សេវាកម្មចាប់ផ្តើមនៅ
ខែមិថុនា ឆ្នាំ 2024។



ស្វែងយល់បន្ថែម៖

**www.fairfieldcity.nsw.gov.au/waste**

# តើ FOGO គឺជាអ្វី ?

**FOGO** តំណាងឲ្យ
សារធាតុសរីរាង្គអាហារ សារធាតុសរីរាង្គសួនច្បារ






ធុងពណ៌បៃតងនិងកូនធុងសំរាមសម្រាប់ចង្ក្រានបាយមួយនឹងត្រូវចែកចាយទៅដល់ទីលំនៅទាំងឡាយនៅក្នុងក្រុង Fairfield ទាំងមូល សម្រាប់ការបោះចោលកាកសំណល់អាហារនិងសួនច្បារ។

ធុងនេះនឹងត្រូវប្រមូល**រៀងរាល់ពេលពីរអាទិត្យ**។

សេវាកម្មនៃធុងកាកសំណល់ពណ៌ក្រហម និងធុងកែច្នៃឡើងវិញពណ៌លឿងរបស់អ្នក នឹងនៅ**ដដែល** – ទំហំនិងថ្ងៃប្រមូលដដែល។

# តើ FOGO នឹងចាប់ផ្តើមនៅថ្ងៃណា ?

ពលរដ្ឋក្នុងក្រុងនឹងទទួលធុងនិងកូនធុងថ្មីរបស់ខ្លួននៅមុនពេលប្រមូលរបស់វាដែលចាប់ផ្តើមនៅ
**ខែមិថុនា ឆ្នាំ 2024**។



# ហេតុអ្វីបានជាយើងត្រូវការ FOGO ?

តើអ្នកដឹងទេថា **60%** នៃកាកសំណល់ដែលយើងផលិតគឺជាសារធាតុសរីរាង្គ ? នៅពេលដាក់ទៅក្នុងធុងពណ៌ក្រហម វាត្រូវបានបញ្ជូនដោយផ្ទាល់ទៅកាន់**កន្លែងចាក់សំរាម**។

FOGO អនុញ្ញាតឲ្យយើង**បង្វែរ**សារធាតុសរីរាង្គចេញពីកន្លែងចាក់សំរាម និងកាត់បន្ថយការបញ្ចេញឧស្ម័នប៉ះពាល់បរិស្ថាន។ សារធាតុសរីរាង្គទាំងនេះត្រូវបានប្រែទៅជាជីកំប៉ុស្តិ៍ ដើម្បីប្រើនៅក្នុងកសិដ្ឋាន សួនឧទ្យាន និងទីលានកីឡា។



នៅក្រោមយុទ្ធសាស្ត្រសារធាតុនិរន្តរភាពនិងកាកសំណល់រដ្ឋ NSW 2041 សាលាក្រុងទាំងអស់ត្រូវមានសេវាកម្ម FOGO ប្រចាំសប្តាហ៍មិនឲ្យហួសពីឆ្នាំ 2030 ឡើយ។

